ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ទំព័រហ្វេសប៊ុករបស់ក្រសួងមុខងារសាធារណៈ ដែលមានអាសយដ្ឋាន www.facebook.com/civilservicecambodia ត្រូវបានក្រុមជនអនាមិក (Hacker) យកទៅគ្រប់គ្រងកាលពីព្រឹកថ្ងៃពុធ **ទី០២ ខែមករា ឆ្នាំ២០១៩**។

ក្នុងអំឡុងពេលនេះ ប្រសិនបើមានការចុះផ្សាយព័ត៌មានណាមួយនៅលើទំព័រហ្វេសប៊ុកនេះ ក្នុងចេតនាអាក្រក់ណាមួយ គឺមិនឆ្លុះបញ្ចាំងពីគោលជំហរ ឬ ព័ត៌មានពិតប្រាកដចេញពីក្រសួងមុខងារសាធារណៈឡើយ ហើយក្រសួងក៏មិនទទួលខុសត្រូវលើផលប៉ះពាល់ណាមួយដែលកើតចេញពីការផ្សព្វផ្សាយព័ត៌មានណាមួយនៅលើទំព័រដែលកំពុងគ្រប់គ្រងដោយក្រុម Hacker នេះដែរ។

ទន្ទឹមនឹងនេះ ក្រុមការងារបច្ចេកទេសរបស់ក្រសួង កំពុងសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីយកទំព័រហ្វេសប៊ុកនេះ មកគ្រប់គ្រងវិញផងដែរ។

ថ្ងៃពុធ ១១រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២ ខែមករា ឆ្នាំ២០១៩

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh